ផ្សារមូលបត្រកម្ពុជា

CSX

ក្រុមហ៊ុន ផ្សារមូលបត្រកម្ពុជា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

*ថ្ងៃពុធ ៨រោច ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២*

*រាជធានីភ្នំពេញ ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១៨*

សេចក្តីជូនដំណឹង

**អំពី**

**សេចក្តីសម្រេចលើពាក្យស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីរបស់**

**ក្រុមហ៊ុន ផេសថិក (ខេមបូឌា) លីមីធីត**

ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (ផ.ម.ក.) បានសម្រេចឯកភាពជាគោលការណ៍លើពាក្យស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីរបស់ ក្រុមហ៊ុន ផេសថិក (ខេមបូឌា) លីមីធីត នៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ ២០១៨។ ដើម្បីអាចចុះបញ្ជី និងជួញដូរជាផ្លូវការបាននៅ ផ.ម.ក. ក្រុមហ៊ុន ផេសថិក (ខេមបូឌា) លីមីធីត ត្រូវទទួលបានការអនុញ្ញាតបោះផ្សាយលក់មូលបត្រជាសាធារណៈពីគណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក.) និង ត្រូវបំពេញលក្ខខណ្ឌតម្រូវផ្សេងៗមួយចំនួនទៀតពាក់ព័ន្ធនឹងការចុះបញ្ជីនៅ ផ.ម.ក.។

សូមបញ្ជាក់ជូនថា ក្រុមហ៊ុន ផេសថិក (ខេមបូឌា) លីមីធីត គឺជាក្រុមហ៊ុនបច្ចេកទេសថាមពលអគ្គិសនីដែលផ្តល់សេវាកម្មចម្បងលើការសាងសង់បណ្តាញបញ្ជូនអគ្គិសនី (Transmission Line), អនុស្ថានីយ៍ (Sub-station), ប្រព័ន្ធថាមពលខ្សែកាបក្រោមដី, និង ការជួញដូរបង្គុំនិងគ្រឿងបរិក្ខារប្រព័ន្ធថាមពល។ ក្រុមហ៊ុន ផេសថិក (ខេមបូឌា) លីមីធីត ត្រូវបានរំពឹងថាជាក្រុមហ៊ុនទីប្រាំមួយដែលនឹងចុះបញ្ជីនៅ ផ.ម.ក.។ ក្រុមហ៊ុននេះមានអាសយដ្ឋានស្ថិតនៅ ផ្ទះលេខ ៦ ផ្លូវលេខ ៥៨៨ សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

**ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា**

Cambodia Securities Exchange